**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាចារ្យអាទិត្យនៃព្រះជាម្ចាស់សម្ដែងមេត្តាករុណានៅព្រះសហគមន៍សន្ដីម៉ារីញញឹម**
**ចំការទៀង ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២០**

# សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ដ

**អត្ថបទទី១៖ កិច្ចការ ២,៤២-៤៧**

សាវ័កទាំងនោះ ព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមគ្រីស្ដទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ង និងព្យាយាមអធិស្ឋាន។ កក ២,៤២

**អត្ថបទទី២៖ ពេត្រុសទី១ ១,៣-៩**

ហើយឫទ្ធានុភាពរបស់ព្រះអង្គថែរក្សាបងប្អូន ដោយសារជំនឿ ដើម្បីឲ្យបងប្អូនទទួលការសង្គ្រោះ ដែលព្រះអង្គបានរៀបចំទុកជាស្រេច ហើយដែលទ្រង់នឹងសម្ដែងនៅគ្រាចុងក្រោយបំផុត។ ១ពត្រ ១,៥

**ដំណឹងល្អ៖ យ៉ូហាន ២០,១៩-៣១**

«អ្នកជឿមកពីអ្នកបានឃើញខ្ញុំ អ្នកណាជឿ ដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គល*ហើយ!»។ យហ ២០,២៩

បងប្អូនជាទីស្រឡាញ់!

"**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ដ**" យើងបានលឺពាក្យនេះបីដង ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញមានព្រះបន្ទូលដល់ក្រុមគ្រីស្ដទូត។ នៅពេលនោះ ក្រុមគ្រីស្ដទូតបានជាប់នៅក្នុងបន្ទប់មួយដោយបិទទ្វារបិទបង្អួចយ៉ាងជាប់ ដោយសារគេខ្លាចក្រុមជនជាតិយូដាដែលមកចាប់គេ គេខ្លាចគេត្រូវទទួលទោសដោយសារគេជាសាវ័ករបស់ព្រះយេស៊ូ។ ថ្ងៃនេះ ជាអភិបូជាក្នុងសប្ដាហ៍ទីពីរនៃរដូវបុណ្យចម្លង ដោយគោរពព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ នៅឆ្នាំ២០០០ សន្ដយ៉ូហានប៉ូលទីពីរ បានណែនាំឲ្យពិភពលោករបស់យើងគោរពព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ដោយយល់ថានេះជាសេចក្ដីត្រូវការរបស់យើង។ ពិភពលោករបស់យើង ត្រូវតែមានសេចក្ដីសុខសាន្ដ ត្រូវតែមានបទពិសោធន៍អំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។

ខ្ញុំជឿថា នៅក្នុងកាលៈទេសៈនេះដោយសារកូវីដ១៩ ពិភពលោករបស់យើងបានប្រែប្រួល យើងជាគ្រីស្ដបរិស័ទក្ដី យើងជាពុទ្ធបរិស័ទក្ដី យើងជាអ៊ីស្លាមបរិស័ទក្ដី យើងជាបរិស័ទនៃសាសនាណាមួយក្ដី យើងទាំងអស់គ្នាកំពុងស្វែងរកសេចក្ដីសុខសាន្ដដែលណែនាំឲ្យយើងអាចមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីតស៊ូទៅមុខនៅក្នុងជីវិតរបស់យើង។ ថ្ងៃនេះ យើងបានចូលនៅក្នុងព្រះវិហារដោយបានបិទទ្វារបិទបង្អួច ដូចក្រុមគ្រីស្ដទូតពីសម័យដើមនៅក្នុងការភ័យខ្លាច។

នៅក្នុងការភ័យខ្លាចរបស់យើងទាំងអស់ យើងលឺព្រះសូរសៀងរបស់ព្រះយេស៊ូដែលមានព្រះបន្ទូលថា "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**"។ ជូនកាលយើងដូចជាក្រុមគ្រីស្តទូត១០នាក់ ដែលកំពុងអង្គុយមើលព្រះយេស៊ូឈរនៅកណ្តាលគេ និងណែនាំឲ្យគេមានសេចក្តីសុខសាន្តពិតមែន។ ជូនកាលយើងដូចលោកថូម៉ាស់ដែរ ដែលមិនបាននៅទីនោះទេ ប៉ុន្តែពេលព្រះយេស៊ូបង្ហាញខ្លួនសាជាថ្មីលោកថូម៉ាស់នៅ គាត់បានត្រៀមខ្លួនដើម្បីដាក់ម្រាមដៃនៅក្នុងស្នាមរបួសរបស់ព្រះយេស៊ូ។ ប៉ុន្តែ មុនដាក់ដៃក្នុងស្នាមរបួសនេះគាត់បានប្រកាសថា "**ព្រះអង្គពិតជាព្រះអម្ចាស់និងជាព្រះរបស់ទូលបង្គំមែន**"។ ដូច្នេះ ថ្ងៃនេះយើងជួបជុំគ្នាដើម្បីអធិដ្ឋានដោយដឹងថា នៅក្បែរយើងមានវត្តមានព្រះយេស៊ូផ្ទាល់ដែលកំពុងនិយាយជាមួយយើងតាមកន្លែងដែលយើងនៅថា "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**"។

បងប្អូនជាទីស្រឡាញ់!

នៅក្នុងស្ថានភាពរបស់យើងពេញមួយខែកន្លងមកនេះ យើងត្រូវតែនឹកឃើញក្រុមគ្រីស្តទូតពីដើម ក្រុមគ្រីស្តបរិស័ទពីដើមដូចក្នុងអត្ថបទទីមួយ "**សាវ័កទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ងនិងព្យាយាមអធិដ្ឋាន**"។ ៣០ឆ្នាំមុន យើងបានបង្កើតព្រះសហគមន៍កម្ពុជាសាជាថ្មី យើងបានសាងសង់ព្រះសហគមន៍របស់យើងសាជាថ្មី ទោះបីជំនឿរបស់យើងមិនបានបាត់បង់ប៉ុន្តែយើងដឹងថា អស់បូជាចារ្យ អស់សកម្មភាព អស់អាគារ អស់អ្វីៗទាំងអស់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩០ ពេលយើងកសាងព្រះសហគមន៍នៅប្រទេសកម្ពុជាសាជាថ្មី យើងបានយកអត្ថបទនេះជាមូលដ្ឋាន ដើម្បីនឹកឃើញក្រុមគ្រីស្តបរិស័ទនិងក្រុមគ្រីស្តទូតពីដើមបានធ្វើអ្វីខ្លះ។

១. គេបានស្តាប់ការបង្រៀនរបស់ក្រុមគ្រីស្តទូតគឺអប់រំជំនឿ

២. គេបានធ្វើពិធីកាច់នំប៉័ង ពិធីបុណ្យនានានិងអធិដ្ឋានដែលគេធ្វើជាប្រចាំ

៣. គេបានរួមរស់ជាមួយគ្នាជាបងប្អូន មានន័យថាជាក្រុមគ្រួសារមួយដែលចេះសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជានិច្ច។

អប់រំជំនឿ អធិដ្ឋាន និងសម្តែងធម៌មេត្តាករុណា ជាមូលដ្ឋានគ្រឹះនៃព្រះសហគមន៍ពីសម័យដើម ដែលត្រូវទៅជាមូលដ្ឋានគ្រឹះរបស់ព្រះសហគមន៍យើងនៅសព្វថ្ងៃតទៅទៀត។

មួយខែដែលយើងមិនអាចជួបជុំគ្នាតាមបែបសាសនា មួយខែដែលយើងបិទទាំងការប្រជុំទាំងសិក្ខាសាលា ទាំងប្រជុំបូជាចារ្យ ទាំងសំណាក់ធម៌ ទាំងកម្មវិធីនានា។ ប៉ុន្តែ ទោះបីយើងបិទ

យើងដឹងថារួមជាមួយភូមិភាគភ្នំពេញ ជាមួយបូជាចារ្យ ជាមួយក្រុមបព្វជិតបព្វជីតា យើងបានចូលរួមអធិដ្ឋានជាមួយគ្នា។ ជាពិសេស ដោយសារការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា (CSC) យើងមានសមត្ថភាពដើម្បីថែរក្សាការអធិដ្ឋានមួយជាមួយគ្នា ដោយបានផ្សព្វផ្សាយទាំងអភិបូជា ទាំងសូត្រផ្គុំ ដើម្បីឲ្យដឹងថាទាំងនៅក្នុងរដូវអប់រំពិសេស ទាំងនៅក្នុងសប្តាហ៍ពិសិដ្ឋ បុណ្យចម្លង បុណ្យចូលឆ្នាំខ្មែរ និងនៅរដូវបុណ្យចម្លង យើងនៅក្នុងរបៀបថ្មីដែលណែនាំឲ្យយើងជិតស្និទ្ធនៅក្នុងការអធិដ្ឋាន។ ប៉ុន្តែ ពេលនេះយើងចូលនៅក្នុងជីវិតធម្មតាវិញម្យ៉ាង យើងអាចធ្វើដំណើរបាន រដូវចូលឆ្នាំខ្មែរចប់ហើយ ទោះបីសាលាយើងបន្តបិទទ្វារ ទោះបីសកម្មភាពបែបសាសនានៅតែហាមដដែល យើងដឹងថាយើងត្រូវការបន្តជីវិត។ យើងមិនអាចបិទទ្វារបិទបង្អួចនៃដួងចិត្តរបស់យើង ដោយថាចាំមួយខែពីរខែឬបីខែទៀត ជាពិសេសសាសនារបស់យើងជាសាសនាគ្រីស្តនិកាយកាតូលិក។

ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ នៅក្នុងសាលារៀនរបស់យើង យើងបានយកចិត្តទុកដាក់ដើម្បីណែនាំឲ្យសិស្សនិស្សិតរៀនតាមអនឡាញ Online (E-Leaning) ជាមួយ Messenger ជាមួយ Facebook ជាមួយ Telegram ដោយមានគ្រូបង្រៀនពីព្រឹកដល់ល្ងាច សិស្សនិស្សិតចូលរៀនតាមនោះពីថ្នាក់ទី៧ដល់ថ្នាក់ទី១២។ នេះជាការយកចិត្តទុកដាក់ ណែនាំឲ្យយើងឃើញថាយើងមានសមត្ថភាព ទោះបីយើងរៀនតាមសាលាមិនបាន យើងមានសមត្ថភាពដើម្បីរកមធ្យោបាយថ្មីដើម្បីណែនាំឲ្យសិស្សនិស្សិតរបស់យើងអាចទៅមុខបាន។ ជាមួយអង្គការការីតាស ជាមួយការិយាល័យសុខភាពកាតូលិក ជាមួយភូមិភាគភ្នំពេញផ្ទាល់ នៅក្នុងមួយខែកន្លងមកយើងមានសកម្មភាពជួបជាមួយបងប្អូនក្រីក្រ ដើម្បីអប់រំអំពីអនាម័យ ដើម្បីចែករំលែកពីរបៀបការពារថែរក្សាសុខភាព។ ជាមួយគណកម្មការសង្គហៈនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង យើងបានជួយ១១០គ្រួសារ ដើម្បីឲ្យគេមានកម្លាំងកាយកម្លាំងចិត្តនៅក្នុងទុក្ខលំបាករបស់គេ។

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងគោរពព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ខ្ញុំសូមឲ្យភូមិភាគភ្នំពេញទាំងអស់ភ្ញាក់ស្មារតី ដើម្បីគិតតាមវិស័យនីមួយៗ **តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទាំងការអធិដ្ឋាន ទាំងការបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង នៅក្នុងជីវិតរបស់យើងជាព្រះសហគមន៍?**

**ទីមួយ** ខ្ញុំសូមអញ្ជើញឲ្យបងប្អូនបន្តអធិដ្ឋានជាប្រចាំថ្ងៃ អានអត្ថបទគម្ពីរដំណឹងល្អ ចូលមើលនៅតាម Facebook និង YouTube ដើម្បីមានអភិបូជានិងសូត្រផ្គុំប្រចាំថ្ងៃ។ នេះជាកម្លាំង

កាយកម្លាំងចិត្តដែលយើងទទួល ដើម្បីមានសេចក្ដីសុខដោយជួបព្រះយេស៊ូផ្ទាល់ដែលមកសួរសុខទុក្ខយើង និងដើម្បីឲ្យយើងមានកម្លាំងទៅមុខ។ ប៉ុន្តែ ខ្ញុំសូមរំលឹកដល់លោកឪពុកទាំងអស់ដល់គ្រូអប់រំជំនឿទាំងអស់ បងប្អូនរបស់យើងមួយចំនួនឥតមានអ៊ីនធើណេត ឥតមានទូរស័ព្ទទំនើបដើម្បីមើលអភិបូជានិងសូត្រផ្ដាំទេ។ ដូច្នេះ សូមរកមធ្យោបាយដោយមានឯកសារ ដោយទៅជួបផ្ទាល់ ដើម្បីឲ្យគ្រីស្ដបរិស័ទយើងមានឱកាសអធិដ្ឋាន យ៉ាងតិចទទួលអត្ថបទដំណឹងល្អជាប្រចាំថ្ងៃ នៅក្នុងរបៀបផ្សេងពី Facebook និង YouTube។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ខាងមុខនេះ ខ្ញុំមានប្រជុំតាមអនឡាញ Online ជាមួយលោកឪពុកដើម្បីឲ្យយើងគិតសាជាថ្មីអំពីបញ្ហានេះ។

**ទីពីរ** ខ្ញុំសូមអញ្ជើញឲ្យបងប្អូនទាំងអស់ ដែលធ្វើការក្នុងវិស័យអប់រំរបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ពីមត្តេយ្យសិក្សារហូតដល់ឧត្ដមសិក្សាឲ្យយើងបន្តជម្រុញដើម្បីទៅមុខសម្រាប់កន្លែងដែលបានធ្វើហើយ។ ចំពោះកន្លែងមិនទាន់បានធ្វើ សូមទៅរកមធ្យោបាយជាពិសេសនៅក្នុងមត្តេយ្យសិក្សា កូនក្មេងនៅតាមភូមិសព្វថ្ងៃឥតមានឱកាសដើម្បីចូលសាលាពិតមែន។ ប៉ុន្តែ យើងជាលោកគ្រូអ្នកគ្រូដែលរស់នៅតាមមូលដ្ឋាននីមួយៗ សូមរកមធ្យោបាយដើម្បីធ្វើលំហាត់ ធ្វើមេរៀន ធ្វើពាក្យកំណាព្យ ធ្វើបទចម្រៀង ធ្វើអ្វីៗដែលអាចឲ្យកូនក្មេងក្នុងមូលដ្ឋានរបស់យើងមានឱកាសរៀនសូត្រ។ កុំឲ្យមួយខែខាងមុខនេះ កូនក្មេងរបស់យើងចាប់ផ្ដើមស្ទិតខួរក្បាលអស់។ ទំនាក់ទំនងជាមួយឪពុកម្ដាយ ជាមួយអាណាព្យាបាលដើម្បីរកមធ្យោបាយថ្មីឲ្យទៅមុខ។

**ទីបី** នៅពេលនេះខ្ញុំសូមឲ្យការិយាល័យអប់រំជំនឿនិងគម្ពីរ រកមធ្យោបាយដើម្បីទំនាក់ទំនងជាមួយបងប្អូនដែលកំពុងរៀនអប់រំជំនឿ។ ជាពិសេសអ្នកកំពុងស្វែងយល់ ជំហានទីមួយ ជំហានទីពីរ រៀបចំឯកសារតាមរបៀបណាមួយ រៀបចំតាម Telegram រៀបចំការអប់រំជំនឿខ្លីៗតាម Facebook ក៏បាន សូមយកចិត្តទុកដាក់ដើម្បីរកមធ្យោបាយ។ អ្វីដែលយើងធ្វើនៅក្នុងកម្រិតភូមិភាគភ្នំពេញ យើងធ្វើដូចម្ដេចដើម្បីឲ្យវាចូលនៅក្នុងមូលដ្ឋាននីមួយៗ។ ដូច្នេះ គ្រូអប់រំជំនឿតាមកន្លែងនីមួយៗសូមទៅរករបៀប ដើម្បីមានទំនាក់ទំនងជាមួយបងប្អូនយើង។ មានខ្លះគាត់អានមិនបាន ប៉ុន្តែសូមយើងរកមធ្យោបាយដើម្បីឲ្យគេបន្តស្វែងយល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យ៉ាងតិច ថែរក្សាព្រះបន្ទូលដើម្បីចិញ្ចឹមជីវិតរបស់បងប្អូនទាំងអស់ ដែលកំពុងទទួលការអប់រំជំនឿពីយើងជាបន្ទាន់។ ដូច្នេះ នៅពេលនោះយើងមានកម្រិតភូមិភាគ និងកម្រិតតាមព្រះសហគមន៍នីមួយៗ។

**ទីបួន** ខ្ញុំសូមនិយាយទៅការិយាល័យយុវជន ជំទង់ និងកុមារកាតូលិកភូមិភាគភ្នំពេញ សូមបន្តយកចិត្តទុកដាក់។ នៅក្នុងមួយសប្តាហ៍ម្តង យើងត្រូវការមានសកម្មភាពតាមកម្រិតជាមួយយុវជន ជាមួយជំទង់ ជាមួយកុមារ ដើម្បីឲ្យកម្មវិធីការិយាល័យទៅមុខ។

**ទីប្រាំ** ខ្ញុំសូមអញ្ជើញគ្រប់អង្គការកាតូលិក គ្រប់ការិយាល័យដែលបង្ហាញមេត្តាករុណា គ្រប់គណកម្មការសង្គហៈនៅក្នុងភូមិភាគភ្នំពេញ ឲ្យយើងយកចិត្តទុកដាក់ដើម្បីបង្កើតសកម្មភាពសម្រាប់មួយខែខាងមុខនេះដើម្បីជួយ ដើម្បីលើកទឹកចិត្ត តាមកន្លែងនីមួយៗ។ នៅក្នុងភូមិភាគភ្នំពេញយើងមានព្រះសហគមន៍៥០កន្លែង ខ្ញុំសូមអញ្ជើញឲ្យយើងមានស្នាដៃធម៌មេត្តាករុណាតូចក៏ដោយ ធំក៏ដោយ តាមសមត្ថភាព។ ដោយបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលបានហៀរចេញពីព្រះបេះដូងរបស់ព្រះយេស៊ូ។ នៅពេលនោះយើងបានឃើញមានទឹកដ៏មានជីវិតដែលណែនាំឲ្យយើងមានកម្លាំងដើម្បីទៅមុខ យើងឃើញឈាមរបស់ព្រះអង្គដែលជាសេចក្តីស្រឡាញ់របស់ទ្រង់ ដែលណែនាំឲ្យយើងទទួលព្រះហឫទ័យប្រណីសន្តោស ការលើកលែងទោសពីព្រះអង្គ ដើម្បីឲ្យយើងផ្ទាល់ខ្លួនទៅជាសាក្សីនៃការលើកលែងទោស ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គចំពោះបងប្អូនឯទៀតៗ។

ដូច្នេះ សូមការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា បង្កើតក្រុមមេត្តាករុណាដើម្បីឲ្យបងប្អូនយើងទាំងអស់ ដែលមានបទពិសោធន៍ចែករំលែកមេត្តាករុណា។ បង្ហោះបទពិសោធនោះទាំងរូបថតសកម្មភាព ទាំងឯកសារដែលយើងបានធ្វើ ដើម្បីឲ្យបងប្អូនផ្សេងៗមានគំនិតដែរ ដោយរកឃើញឯកសារខ្លះ គំនិតខ្លះដើម្បីឲ្យយើងបង្ហាញធម៌មេត្តាករុណា។ ខ្ញុំចង់មានឧបករណ៍មួយ ដើម្បីឲ្យយើងប្រមូលយោបល់របស់យើងនៅក្នុងធម៌មេត្តាករុណា ទាក់ទងអនាម័យ ទាក់ទងកសិកម្ម...។ ដោយសារ បន្តិចទៀតបងប្អូនរបស់យើងមួយចំនួនគេពិបាករកស៊ី ពិបាករកចំណូល ប៉ុន្តែគេអាចដាំបន្លែ ចិញ្ចឹមសត្វ...។ យើងរៀបចំឧបករណ៍មួយ ដើម្បីប្រមូលយោបល់យើងទាំងអស់ ឯកសារយើងទាំងអស់ ដើម្បីផ្សព្វផ្សាយដល់កន្លែងផ្សេងៗតទៅទៀត។

បងប្អូនជាទីស្រឡាញ់!

ភូមិភាគភ្នំពេញ ត្រូវតែទៅមុខក្នុងរយៈពេលមួយខែនេះ ដោយដឹងថាជីវិតដែលយើងទទួលពីព្រះយេស៊ូ ជាអំណោយទានដែលយើងត្រូវតែចែករំលែក។ ថ្ងៃនេះ យើងបង្ហាញអំពីសេចក្តីស្រឡាញ់របស់យើង អំពីជំនឿរបស់យើង ដោយបង្ហាញថាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញពណ៌ស ព្រះយេស៊ូដែលមានឈាមហូរចេញពីព្រះបេះដូងព្រះអង្គ ដើម្បីលើកលែងទោសឲ្យមនុស្សយើងពណ៌ក្រហម និងព្រះយេស៊ូមានទឹកដែលផ្តល់ជីវិត ទឹកដែលជម្រះចិត្តគំនិតរបស់

យើងពណ៌ខៀវ ដើម្បីទទួលការសង្គ្រោះតាមរបៀបដែលសន្ទីហ្វស៊ីណា និងសន្តយ៉ូហានប៉ូលទីពីរ បានណែនាំឲ្យពិភពលោកយើងភ្ជាប់ជាមួយព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ អាម៉ែន៕